# វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣

វិមានរដ្ឋាភិបាល (CDC)

រាជធានីភ្នំពេញថ្ងៃទី ០២-០៣ មិថុនា ឆ្នាំ២០១០

របៀបវារៈទី III : កម្មវិធីកំណែទម្រង់ជាអាទិភាពដើម្បីសម្រេចនូវគោលដៅសហស្សវត្សកម្ពុជា

## វិមជ្ឈការ និងវិសហមជ្ឈការ

បទបង្ហាញដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

និងជាប្រធាន គ.ជ.អ.ប

- **សូមគោរពឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរពរាប់អាន!**

ក្នុងនាមគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គប្រជុំដែលបានផ្តល់ឱកាសដល់ខ្ញុំ ដើម្បីបង្ហាញដោយសង្ខេប អំពីវឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងបញ្ហាប្រឈមនានាដែលជួបប្រទះក្នុងរយៈពេលនៃការអនុវត្តកំណែទម្រង់នេះ។

ដូចឯកឧត្តម លោកជំទាវ លោក លោកស្រី បានជ្រាបហើយថា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលបានអនុម័តនៅឆ្នាំ២០០៨ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ បានកំណត់ពីរដ្ឋបាលឯកភាពនៅថ្នាក់ក្រោមជាតិ និងបានអនុញ្ញាតិឱ្យមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាដែលបានរៀបចំឡើងកាលពីឆ្នាំកន្លងទៅនេះ។ ជាមួយគ្នានេះដែរ លិខិតបទដ្ឋានគតិយុត្តទាំងនេះ បានតម្រូវអោយបង្កើតគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍន៏តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដើម្បីដឹកនាំ និងសម្របសម្រួលការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងបទបញ្ញត្តិនានានៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ហើយក៏បានផ្តល់ជាមូលដ្ឋានសម្រាប់ការរៀបចំតាក់តែង

កម្មវិធីជាតិរយៈពេលមធ្យម និងរយៈពេលវែងដើម្បីធានាដល់ការអនុវត្ត។

ក្នុងន័យនេះ គ.ជ.អ.ប បានបង្កើតនូវក្រុមការងារមួយដែលបានចាប់ផ្តើមការងាររបស់ខ្លួននៅខែកញ្ញា ឆ្នាំ២០០៨ ក្នុងការរៀបចំកម្មវិធីជាតិមួយដែលមានរយៈពេល១០ឆ្នាំ ដោយប្រើប្រាស់នូវវិធីសាស្ត្រនានា ដើម្បីធានាឱ្យមានការចូលរួម និងការពិគ្រោះយោបល់យ៉ាងសកម្មពីអ្នកពាក់ព័ន្ធទាំងអស់ក្នុងដំណើរការនៃការរៀបចំកម្មវិធីនេះ។ ជាក់ស្តែង ក្រុមងាររៀបចំកម្មវិធីជាតិ បានរៀបចំការពិភាក្សាពិគ្រោះយោបល់ផ្នែកគោលនយោបាយចំនួន៥លើកទៅលើប្រធានបទសំខាន់ៗ ដែលលទ្ធផលនៃការពិភាក្សាពិគ្រោះយោបល់ទាំងនេះត្រូវបានប្រើប្រាស់ជាសំខាន់ក្នុងការរៀបចំកម្មវិធីជាតិ។ យើងទទួលស្គាល់ថា នេះជាកិច្ចដំណើរការប្រកបដោយលក្ខណៈលំបាកស្មុគស្មាញ និងទាមទារនូវពេលវេលាសមស្រប ប៉ុន្តែវាមានសារៈសំខាន់សម្រាប់ធានាដល់ការអនុវត្តប្រកបដោយជោគជ័យ។ ជាលទ្ធផល សេចក្តីព្រាងចុងក្រោយនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩ ត្រូវបានពិនិត្យ ពិភាក្សា និងអនុម័តដោយ គ.ជ.អ.ប នៅខែមីនា ឆ្នាំ២០១០ ហើយបន្ទាប់មក ត្រូវបានរាជរដ្ឋាភិបាលពិនិត្យ និងអនុម័តនៅថ្ងៃទី២៨ ខែឧសភា នាពេលថ្មីៗកន្លងមកនេះ។

បច្ចុប្បន្ន គ.ជ.អ.ប ស្ថិតនៅក្នុងដំណាក់កាលនៃការចាប់ផ្តើមនៃការអនុវត្តកម្មវិធីជាតិ។ ពាក់ព័ន្ធនឹងការងារនេះ គ.ជ.អ.ប កំពុងរៀបចំផែនការអនុវត្តរយៈពេល៣ឆ្នាំ (២០១១-២០១៣) ហៅកាត់ថា "ផអ៣" ដែលមានរួមបញ្ចូលនូវកម្មវិធី និងថវិកាលម្អិតសម្រាប់ឆ្នាំ២០១១ផងដែរ។ លើសពីនេះទៀត ដើម្បីបង្ហាញឱ្យកាន់តែច្បាស់អំពីសមាសធាតុទាំង៥នៃកម្មវិធីជាតិ ផែនការអនុវត្តរយៈពេល៣ឆ្នាំនេះ នឹងបញ្ចូលនូវការផ្តួចផ្តើម និងការវិនិយោគសម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាននានា។ ផ្អែកតាមគោលនយោបាយនានារបស់រាជរដ្ឋាភិបាល គ.ជ.អ.ប កំពុងរៀបចំតាក់តែងផែនការអនុវត្តរយៈពេល៣ឆ្នាំ ដោយប្រើប្រាស់នូវវិធីសាស្ត្រផ្អែកលើកម្មវិធី សម្រាប់ការគាំទ្រ និងកិច្ចសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍នានា។ ចំណុចនេះ ត្រូវបានចាត់ទុកថាគឺជាការរីកចំរើនថ្មីមួយ ប៉ុន្តែវាក៏ជាបញ្ហាប្រឈមថ្មីមួយដែរ ដោយសារវាទាមទារនូវពេលវេលា និងកិច្ចខិតខំប្រឹងប្រែងមួយ ដើម្បីធ្វើការផ្លាស់ប្តូរពីវិធីសាស្ត្រផ្អែកលើគម្រោង មកប្រើប្រាស់វិធីសាស្ត្រផ្អែកលើកម្មវិធីវិញ។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងខិតខំដឹកនាំ និងសម្របសម្រួលក្នុងការលើកកំពស់ការប្រើប្រាស់វិធីសាស្ត្រនេះ និងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានាដើម្បីធានាថា រចនាសម្ព័ន្ធរបស់កម្មវិធីជាតិត្រូវបានរៀបចំឡើងតាមមធ្យោបាយមួយ ដែលអនុញ្ញាតិអោយដៃគូអភិវឌ្ឍន៍ទាំងអស់អាចធ្វើការផ្លាស់ប្តូរប្រកបដោយជោគជ័យនូវរបៀបគាំទ្រដែលមាននាពេលបច្ចុប្បន្ន ឱ្យមកជាការគាំទ្រតាមវិធីសាស្ត្រផ្អែកលើកម្មវិធីវិញ។

ក្នុងន័យនេះ យើងរំពឹងថា ការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍នានាអាចធ្វើសុខដុមនីយកម្មនៅក្នុងផែនការអនុវត្ត រយៈពេល៣ឆ្នាំដំបូង ហើយយើងសង្ឃឹមថា ការគាំទ្រទាំងនេះនឹងត្រូវបានធ្វើសមាហរណកម្មយ៉ាងពេញលេញ ក្នុងផែនការអនុវត្តរយៈពេល៣ឆ្នាំ ដំណាក់កាលបន្ទាប់ពីឆ្នាំ២០១៤-២០១៦។

ដើម្បីសម្រេចបាននូវគោលនយោបាយ និងកម្មវិធីនានាពាក់ព័ន្ធនឹងវិមជ្ឈការ និងវិសហមជ្ឈការ យើងកំពុងតែចាប់ផ្តើមអនុវត្តនូវកម្មវិធីដ៏សំខាន់មួយ សម្រាប់ឱ្យមានការផ្លាស់ប្តូរ ហើយប្រាកដណាស់ថា ការងារនេះនឹងជួបនូវបញ្ហាប្រឈមជាច្រើន។ ជាបឋម ត្រូវធានាឱ្យបានថា កម្មវិធីជាតិគឺជាកម្មវិធីរបស់ក្រសួង ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល។ ជារួម ការផ្តោតការយកចិត្តទុកដាក់ជាសំខាន់របស់កម្មវិធីនេះ គឺទៅលើ ថ្នាក់ក្រោមជាតិនានា ប៉ុន្តែយើងក៏ត្រូវយកចិត្តទុកដាក់ដោះស្រាយបញ្ហានានារបស់ថ្នាក់ជាតិផងដែរ ដោយសារ តួនាទីក្រសួង ស្ថាប័ននានា ពិតជាមានសារសំខាន់បំផុតសម្រាប់ភាពជោគជ័យនៃកម្មវិធីនេះ។ តាមការពិត ភាគច្រើននៃកម្មវិធីនេះ នឹងត្រូវអនុវត្តដោយក្រសួង ស្ថាប័ននានា ដែលក្នុងនោះក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ នឹងធ្វើការដឹកនាំក្នុងផ្នែកសំខាន់ៗមួយចំនួនដូចជា កំណែទម្រង់នៃការសាងផែនការ ហិរញ្ញវត្ថុ និងធនធាន មនុស្សជាដើម។ ជាការពិត កំណែទម្រង់ទាំងនេះមានការពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធ ហើយប្រសិនបើគ្មាន វឌ្ឍនភាពក្នុងផ្នែកណាមួយ នឹងជះឥទ្ធិពលដល់ផ្នែកដទៃទៀតមិនខាន។ ជាក់ស្តែង ការអនុវត្តកំណែទម្រង់ ហិរញ្ញវត្ថុ គឺពិតជាមានសារសំខាន់បំផុត ព្រោះថា ប្រសិនបើគ្មានប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយតម្លាភាព គណនេយ្យភាពជាមួយការផ្តល់ហិរញ្ញប្បទានយ៉ាងសមស្រប និងដែលអាចព្យាករណ៍បានដល់រដ្ឋបាលថ្នាក់ ក្រោមជាតិនោះទេ នោះវឌ្ឍនភាពនៃការអនុវត្តផ្នែកដទៃទៀតនៃកម្មវិធីជាតិ នឹងមិនអាចដំណើរការបាន ប្រកបដោយប្រសិទ្ធភាពឡើយ។

ជាទូទៅក្រសួង ស្ថាប័ននានាសុទ្ធតែមានតួនាទីសំខាន់បំផុត ក្នុងការអនុវត្តនៅតាមវិស័យនានារបស់ខ្លួន ដែលក្នុងនោះរួមមាន ការរៀបចំគោលនយោបាយ ការកំណត់ស្តង់ដារ និងការរៀបចំសេចក្តីព្រាង និងអនុម័ត នូវច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ក្រុមប្រឹក្សានៃរដ្ឋបាលមូលនានានៅថ្នាក់ក្រោមជាតិ ត្រូវបានបង្កើត ឡើងរួចហើយ ហើយរចនាសម្ព័ន្ធថ្មីនានានៅថ្នាក់ក្រោមជាតិក៏បាន និងកំពុងបង្កើតឡើងនាពេលបច្ចុប្បន្ន ដើម្បីគាំទ្រដល់កិច្ចដំណើរការកំណែទម្រង់នេះ។ រចនាសម្ព័ន្ធ និងប្រព័ន្ធថ្មីៗទាំងនេះមានភាពចំបាច់បំផុត ដើម្បីធានាដល់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមបែបប្រជាធិបតេយ្យ។ រដ្ឋបាលថ្នាក់ ក្រោមជាតិទាំងនេះចាំបាច់ត្រូវមានការគាំទ្រខាងផ្នែកកសាងផែនការ ប្រព័ន្ធរដ្ឋបាល និងការគ្រប់គ្រងបុគ្គលិក របស់ខ្លួនរួមទាំងការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផងដែរ។ ទាំងនេះ គឺជាបញ្ហាប្រឈមជាគន្លឹះ និង

ទាមទារឱ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួង ស្ថាប័ននានា និងកិច្ចសហការយ៉ាងជិតស្និទ្ធពីកំណែទម្រង់ដ៏សំខាន់ទាំង៣របស់រាជរដ្ឋាភិបាល គឺកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការ។ កម្មវិធីជាតិក៏បានផ្តោតយ៉ាងសំខាន់ទៅលើបញ្ហានេះ ហើយសកម្មភាពពាក់ព័ន្ធនានាដែលត្រូវអនុវត្ត នឹងត្រូវបញ្ចូលក្នុងផែនការអនុវត្តរយៈពេល៣ឆ្នាំ ដើម្បីធានាថា កិច្ចសហការទាំងនេះ នឹងត្រូវបានយកចិត្តទុកដាក់។

ក្រសួង ស្ថាប័ននានា ក៏នឹងត្រូវដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំប្រគល់មុខងារឡើងវិញ ដែលការងារនេះ គឺជាបញ្ហាប្រឈមសម្រាប់ក្រសួង ស្ថាប័នទាំងនោះ។ ពាក់ព័ន្ធនឹងបញ្ហានេះ ក្រសួង ស្ថាប័នទាំងអស់នឹងទទួលខុសត្រូវក្នុងការវិភាគ និងការបន្សុីគ្នាឡើងវិញនូវតួនាទី និងមុខងារទាំងឡាយរបស់ខ្លួន ដើម្បីពិនិត្យមើលឡើងវិញនូវគោលនយោបាយ លិខិតបទដ្ឋានគតិយុត្តនានា និងមុខងារត្រួតពិនិត្យរបស់ខ្លួន ដើម្បីរៀបចំប្រគល់ឡើងវិញនូវមុខងារក្នុងការផ្តល់សេវាទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការងារនេះ នឹងធ្វើឱ្យមានការផ្លាស់ប្តូរជាសំខាន់ទៅលើប្រព័ន្ធអភិបាលកិច្ច និងមុខងារផ្តល់សេវាដែលមាននាពេលបច្ចុប្បន្ន នៅគ្រប់លំដាប់ថ្នាក់រដ្ឋបាលទាំងអស់។ ជាមួយគ្នានេះដែរ គ.ជ.អ.ប ក៏មានតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួលដំណើរការនេះ ដូចមានចែងនៅក្នុងច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងត្រូវធានាថា ដំណើរការនៃការរៀបចំប្រគល់មុខងារឡើងវិញនេះ នឹងត្រូវបានអនុវត្តតាមដំណើរការរួមគ្នាមួយដែលមានតម្លាភាព សម្រាប់គ្រប់វិស័យទាំងអស់ ហើយក្រសួង ស្ថាប័នទាំងនោះនឹងទទួលបានការគាំទ្រយ៉ាងសមស្រប ក្នុងការអនុវត្តដំណើរការនេះ។ ជាងនេះទៀត ក្រសួង ស្ថាប័ននានា នឹងត្រូវជួយគាំទ្រក្នុងការកសាងសមត្ថភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការអនុវត្តតួនាទី និងការទទួលខុសត្រូវថ្មី។

ដោយឡែក ដៃគូអភិវឌ្ឍន៍ទាំងអស់ ក៏អាចដើរតួនាទីរបស់ខ្លួនក្នុងការដោះស្រាយនូវបញ្ហាប្រឈមទាំងនេះដែរ។ រាជរដ្ឋាភិបាល សង្ឃឹមថាដៃគូអភិវឌ្ឍន៍ទាំងអស់នឹងអនុម័តនូវវិធីសាស្ត្រ ដែលមានលក្ខណៈផ្សារភ្ជាប់ជាមួយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការសម្រាប់រាល់គម្រោង និងកម្មវិធីដែលខ្លួនគាំទ្រដល់វិស័យនានា ដើម្បីធានាថា គម្រោង និងកម្មវិធីទាំងនេះមានការបន្សុីគ្នាយ៉ាងល្អប្រសើរជាមួយនឹងកម្មវិធីជាតិ។ យើងខ្ញុំសង្ឃឹមថា បញ្ហាបន្សុីគ្នាអាចនឹងត្រូវបានលើកឡើង ដើម្បីពិភាក្សានៅក្នុងកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសនានា ដើម្បីសម្របសម្រួលកិច្ចដំណើរការឆ្ពោះទៅរកវិធីសាស្ត្រដែលមានលក្ខណៈផ្សារភ្ជាប់គ្នានេះ ដែលខ្ញុំសូមអនុញ្ញាតិហៅថាជា " **វិធីសាស្ត្ររួមរបស់ដៃគូអភិវឌ្ឍន៍នានា** "។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាទីគោរពរាប់អាន!**

ផ្អែកតាមការគ្រោងទុកសម្រាប់របៀបវារៈនេះ ខ្ញុំសូមអនុញ្ញាតិបញ្ចប់យោបល់របស់ខ្ញុំដោយសង្ខេបត្រឹមនេះ ដើម្បីរង់ចាំស្តាប់នូវបទបង្ហាញរបស់ដៃគូអភិវឌ្ឍន៍ ហើយខ្ញុំមានសេចក្តីរីករាយក្នុងការបកស្រាយបន្ថែមលើប្រធានបទនេះ ឬបញ្ហានានាពាក់ព័ន្ធនឹងវិមជ្ឈការ និងវិសហមជ្ឈការ និងកម្មវិធីជាតិនៅក្នុងកម្មវិធីពិភាក្សា។

**សូមអរគុណ!**